«ប្រជាប្រិយ» លេខ ៣០២ ១-១០ កុម្ភៈ ២០០៥



បារមីរបស់ព្រះអង្គដងកើបានជះឥទ្ធិពលលើប្រជាជនដែលរស់នៅក្នុងប្រទេសកម្ពុជា ហើយមានជំនឿលើព្រះពុទ្ធសាសនា និង ការបន់ស្រន់សូមសេចក្ដីសុខបំបាត់នូវទុក្ខកង្វល់ទាំងឡាយ នាំគ្នាមកគោរពអុជធូបបួងសួង បានធ្វើឱ្យទីសំណាក់របស់ព្រះអង្គដែលមានទីតាំងស្ថិតនៅមហាវិថីព្រះស៊ីសុវត្ថិ ខាងកើតព្រះបរមរាជវាំងពោរពេញដោយផ្សែងធូប និង ភាពអ៊ូអរនារសៀលថ្ងៃសីល ក៏ដូចជាថ្ងៃធម្មតា ។

ព្រះអង្គដងកើនេះត្រូវបានបំផ្លាញម្ដងរួចមកហើយ ក្នុងជំនាន់ ប៉ុល ពត ពីឆ្នាំ ១៩៧៥-១៩៧៩ តែដោយសារបុញ្ញហេតុនៃជំនឿរបស់ប្រជាជន គណៈកម្មការកសាងមួយក៏ត្រូវបានបង្កើតឡើង ហើយចាប់ដំណើរការសាងសង់ពីថ្ងៃទី ១៥ ខែមីនា ឆ្នាំ ១៩៩១ ហើយស្រេចជាស្ថាពរ និង ប្រារព្ធពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ១៩៩១ ។

ចំពោះបញ្ហានៃការកកើតព្រះអង្គដងកើឡើង ក្រោយពីការស្រាវជ្រាវតាមរយៈសៀវភៅ និង ការសាកសួរចាស់ព្រឹទ្ធាចារ្យ ព្រះសង្ឃ ដែលគង់នៅភ្នំពេញអស់រយៈពេលជាយូរយារណាស់មកហើយដែលអាចដឹងតៗគ្នាមកនៅថ្ងៃនេះបានអាចជាលទ្ធផលដល់កូនចៅជំនាន់ក្រោយតាមប្រភពផ្សេងៗពីគ្នា ។

# ជំនឿលើព្រះអង្គដងកើ

## ជំនឿតៗគ្នា



មានលោកតាចាស់ម្នាក់ជាមនុស្សពិការភ្នែក តែគាត់ក៏បានដឹងពីប្រវត្តិរបស់ព្រះអង្គដងកើ គាត់បានមានប្រសាសន៍លើកឡើងថា កាលដើមឡើយ រៀងរាល់ថ្ងៃសីល ឬ ថ្ងៃពេញបូណ៌មី គេតែងឃើញមានទង់ក្រពើ ឬ ទង់ក្អែកមានជងមួយតែចុងបែកចេញជាបី ។ ប្រជាជនប្រុសស្រីតែងប្រទះឃើញទង់ប្រភេទនេះផុសនៅទីនេះស្ទើរតែគ្រប់ៗគ្នា ។ តែការផុសឡើងនោះមិនផុសឡើងក្នុងរយៈពេលយូរទេ គឺតែមួយភ្លែតៗហើយក៏លិចបាត់ទៅវិញ ។ ដូច្នេះរៀងរាល់ថ្ងៃសីល ប្រជាជនតែងនាំកូនចៅទៅឈររមើលទង់នេះ ហើយក៏បានធ្វើពិធីបួងសួងប្រគំភ្លេងលាបំណាន់ ឬ ក៏បន់ស្រន់ ដើម្បីសុំជោគជ័យសិរីមង្គលវិបុលសុខគ្រប់ប្រការផង ។

ដោយសារមានជំនឿលើការបន់ស្រន់បែបនេះ ប្រជាជនមានបំណងចង់ឱ្យទង់នេះសណ្ឋិតនៅទីនោះជានិច្ចកាល ហើយក៏នាំគ្នាធ្វើទង់មួយជានិមិត្តរូបនៃទង់ដែលផុស ហើយក៏បានតម្កល់និមិត្តរូបនោះដើម្បីគោរព និង ធ្វើការបន់ស្រន់ ។ តាំងពីធ្វើបាននូវទង់និមិត្តរូបនោះ ទង់ដែលធ្លាប់ផុសនោះក៏លែងផុសទៀតរហូតមក ។ ដោយហេតុនេះប្រជាជនក៏កត់សម្គាល់ថា ទង់និមិត្តរូបដែលប្រតិស្ឋានទុកនៅទីនោះគឺពិតជាតំណាងទង់ដែលផុសនោះឯង ។ ចាប់ពីពេលនោះ កន្លែងនេះបានក្លាយទៅជាកន្លែងធ្វើពិធីបួងសួងបន់ស្រន់សុំសុខចម្រើនរបស់ប្រជាជនរៀងរាល់ថ្ងៃពិសេសនៅថ្ងៃសីល ព្រោះគេជឿថា វត្ថុស័ក្ដិសិទ្ធិជួយរំលែក និង រំដោះទុក្ខភ័យគេបាន ។



ថ្ងៃនេះជាថ្ងៃសីលមានមនុស្សច្រើនណាស់ដែលបានទៅបន់ស្រន់

កាលដ៏យូរលង់ នៅមុខវាំងនេះមានតែទីត្រង់ដងកើនេះទេដែលជាទួលមានព្រៃឈើព្រឈើងព្រពៃបដុះប្របនឹងដងដៃទន្លេសាប ។ ទីនេះមានចំណតផែដ៏ធំដែលមនុស្សម្នាមហាជនអ្នកលក់ដូរខ្មែរ ចិន យួន ដែលចេញចូលទៅមកប្រកបរអាជីវកម្មប្រចាំថ្ងៃ ។ គេជឿ និង ទទួលស្គាល់ថា ត្រង់ទួលព្រៃព្រឈើងព្រពៃបនេះមានវត្ថុស័ក្តិសិទ្ធិណាមួយអាចយកជាទីពឹងជួយសង្គ្រោះចំពោះរូបគេបាន ។ ព្រោះហេតុនេះហើយបានជាមុនពេលចេញដំណើរទៅរកស៊ីលក់ដូរ ឬ ទៅប្រកបការងារអ្វីមួយ គេតែងបួងសួងសម្បុងសង្រួងបន់ស្រន់ចំពោះអស់លោកអ្នកមានឫទ្ធិចេស្តាត្រង់កន្លែងចំណតផែនេះ ដើម្បីសុំសុខចម្រើនជោគជ័យ ។ តាមរឿងតំណាលថានៅពេលយប់ជារៀងរាល់យប់គេតែងឃើញមានដុំភ្លើងហោះពីទីព្រៃនៅត្រង់ដងកើ ទៅកប់បាត់ទៅក្នុងវាំង ហោះចេញពីក្នុងវាំងមកកប់បាត់នៅត្រង់ព្រៃដងកើនេះ ។ ដុំភ្លើងនោះមានពណ៌សក៏មាន ខៀវក៏មាន ចម្រុះពណ៌ស-ខៀវក៏មានហោះធ្លោចុះឡើងទៅមកៗ ។ អ្នកបានឃើញដុំភ្លើងហោះនោះតែងតែព្រឹក្បាលព្រឹស្បែកគ្រប់ៗគ្នា ។ ចាស់ទុំជំនាន់នោះគេសម្គាល់ថា ដុំភ្លើងនោះជាតំណាងវត្ថុស័ក្តិសិទ្ធិអ្វីមួយ ហើយមានទីលំនៅពិតប្រាកដនៅត្រង់ព្រៃឈើត្រង់ទួលដងកើនោះ



ឯង ។ ម្ល៉ោះហើយគេក៏នាំគ្នាកសាងជាអាស្រមនៅត្រង់ដងកើ ទុកជាលំនៅឋានដ៏សមរម្យជូនអស់លោកអ្នកមានឥទ្ធិពលមហិទ្ធិឫទ្ធិ ដើម្បីងាយស្រួលដល់ការធ្វើពលិការផ្សេងៗរបស់ប្រជាជនអ្នកមានជំនឿ ។

តំណពីនោះមក កន្លែងដងកើនេះក្លាយទៅជាកន្លែងបួងសួងសម្បុងសង្រួងបន់ស្រន់ដ៏ស័ក្តិសិទ្ធិរបស់ប្រជាជនខ្មែរអ្នកមានជំនឿ ។ មិនតែប៉ុណ្ណោះកងទ័ពខ្មែរដែលមានឥទ្ធិពលល្បីល្បាញក្នុងការធ្វើសឹកសង្គ្រាមជ័យមិនដែលចាញ់ខ្មាំងសត្រូវទាំងទ័ពជើងទឹក ទ័ពជើងគោក មុនចេញទៅធ្វើសឹកសង្គ្រាមកម្ចាត់មារសត្រូវការពារមាតុភូមិ ការពារប្រជាជន ក៏សុទ្ធតែធ្វើពិធីបួងសួងបន់ស្រន់សុំពរជ័យឫទ្ធិចេស្តាបារមី នៅត្រង់ដងកើនេះមិនដែលលោះខាន ។ ក្រោយពីពិធីបួងសួងសុំពរជ័យហើយគេស្រែកជយឃោសន៍ ពង្រីកភាពស្វាហាប់ ក្លាហាន ទ្រហឹងអឹងកងទើបចេញដំណើរ ហើយតែងផណ្តើមបានជោគជ័យក្នុងសឹកសង្គ្រាម ។

ចំពោះប្រវត្តិស្តូបព្រះអង្គដងកើនេះ បើតាមចាស់ៗដែលធ្លាប់រស់នៅម្តុំនេះនិយាយតំណាលឱ្យដឹងថា ស្តូបនេះប្រហែលជាកសាងឡើងក្រោយពេលកសាងព្រះរាជវាំងចតុម្មុខសព្វថ្ងៃនេះ គឺនៅដើមសតវត្សរ៍ទី ២០ ។ ឯដងកើ «ដងទង់» គេសង់ជាក្រោយទេ សម្រាប់បង្ហូតទង់របស់ព្រះមហាក្សត្រនៅមុខវាំង គឺទង់ព្រះរាជសង្ហារ ។ រីឯផ្លូវដែលចេញពីវាំងត្រង់ទ្វារធំកណ្តាលឆ្ពោះទៅមាត់ទន្លេ ជាផ្លូវសម្រាប់ស្តេចយាងចុះកំពង់ផែ ដើម្បីធ្វើដំណើរទៅខេត្ត-ខណ្ឌ ដែលនៅជាប់នឹងមាត់ទន្លេ និង យាងទៅក្រុងព្រៃនគរ ពីមុនផ្លូវនេះឈ្មោះ «ផ្លូវប្រជាប់ក្រុង» ។ ជំនាន់នោះ មិនទាន់មានផ្លូវគោកសម្រាប់ទៅក្រុងព្រៃនគរទេ ។ ដូច្នោះការធ្វើដំណើរតាមផ្លូវទឹកអាចមានភ័យអាសន្នដោយមានព្យុះខ្យល់នៅរដូវភ្លៀងបានជាមុននឹងចេញដំណើរគេតែងតែបន់ស្រន់សុំពរជ័យពីទេសបារមីវាំង និង ព្រះអង្គដងកើនេះ សុំឱ្យគេធ្វើដំណើរបានសុខសប្បាយ ។ ម្យ៉ាងទៀតនៅពេលគេជួបគ្រោះអាសន្នក្នុងពេលធ្វើដំណើរក៏គេបន់ស្រន់ចំពោះព្រះអង្គដងកើដែរ ។

មានការនិទានតៗគ្នាថា ដើមឡើយនៅខាងកើតដងកើនេះ មានកំពង់ផែមួយដ៏ធំ ជាទីចេញចូលធ្វើដំណើរពីភ្នំពេញទៅខេត្ត-ខណ្ឌជាប់ដងទន្លេ និងពីខេត្ត-ខណ្ឌជាប់ដងទន្លេមកភ្នំពេញរបស់មនុស្សម្នាមហាជនគ្រប់ស្រទាប់ ក្នុងបេសកកម្មបម្រើការងាររាជការ និង ការប្រកបរបរអាជីវកម្មផ្សេងៗ ។

ដើម្បីងាយស្រួលក្នុងការថែរក្សាដាក់សម្ភារៈទំនិញគ្រឿងឧបភោគ-បរិភោគដែលត្រូវចុះឡើង ទូក កាណូត កប៉ាល់ផង និង ដោយទីនេះជាប្រភពដីល្បាប់មានជីជាតិផ្តល់ទិន្នផលច្រើនក្នុងវិស័យកសិកម្មដាំដុះផង គេទាំងឡាយក៏បានសាងសង់ជាផ្ទះតូចៗនៅក្បែរកំពង់ផែនោះ ។ ចំណេរតមកដោយជីវភាពចេះតែមានកម្រិតរីកចម្រើន ប្រជាជននៅទីនេះក៏នាំគ្នាសាងសង់ជាផ្ទះធំទ្រនំខ្ពស់ជាបន្តបន្ទាប់កកើតទៅជាភូមិមួយឈ្មោះថា «ភូមិកំពង់ផែ» ។ ភូមិកំពង់ផែនេះជាភូមិកំណើតរបស់ព្រះមហាវិមលធម៌«ថោង» ចាងហ្វាងសាលាបាលីជាន់ខ្ពស់ជំនាន់ទី ១ ។ ប៉ុន្តែអាស្រ័យដោយទឹកជំនន់ ច្រាំងទន្លេច្រោះបាក់ជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ ទើបភូមិកំពង់ផែត្រូវរលាយបាត់ឈ្មោះ ។ ឯអ្នកភូមិកំពង់ផែ





ទាំងប៉ុន្មានក៏ទៅរកទីលំនៅផ្សេងៗតាមការចូលចិត្តរៀងៗខ្លួន ។ រីឯដងកើ និងវិហារទាំងពីរក៏ចេះតែរំកិលតាមច្រាំងទន្លេបាក់ ហើយក៏បានមកប្រតិស្ឋានស្ថិតនៅកន្លែងសព្វថ្ងៃនេះ ។

វិហារតូចពីរនៅត្រង់ព្រះអង្គដងកើ ដែលត្រូវគេបំផ្លិចបំផ្លាញចោលក្នុងអំឡុងឆ្នាំ ១៩៧៥-៧៨ នោះ កសាងឡើងទន្ទឹមនឹងការកសាងប្រាសាទទេវា-ភោជនីយ ប្រាសាទចន្ទច្ឆាយា ប្រាសាទសិរីទ្ធិវិមានសម្រាន្តភិរម្យ ក្នុងរជ្ជកាលសម្តេចព្រះបាទព្រះស៊ីសុវត្ថិ នាឆ្នាំ ១៩១៣ ។ តែពុំដឹងថាអ្នកណាជាអ្នកកសាងទេ ។ ប្រហែលជាស្នាដៃអ្នកមានជំនឿតាមព្រហ្មញ្ញសាសនា ។ វិហារខាងត្បូងមានឃើញតម្កល់រូបលោកេស្វរៈដៃ ៨ ទ្រង់ឈរ ។ ឯវិហារខាងជើងពុំឃើញរូបសំណាកអ្វីទេ ។ ក្រោយមកលោកឃើញមានដាក់សម្ភារៈឧកញ៉ាពិភក្តិភេត្រា

នាយផ្នែកនាវាចរណ៍ព្រះរាជទ្រព្យ ។



## «ដងកើ» មានន័យថាយ៉ាងដូចម្ដេច ?

វចនានុក្រមខ្មែរ «កើ» ភាសាវៀតណាម ប្រែថា «ទង់» ដងកើ គឺដងទង់ ។

មជ្ឈដ្ឋានខ្លះនិយាយថា ពាក្យ «កើ» នេះគឺប្រហែលជាពាក្យខ្មែរ ពីដើមសរសេរមាន «រ» គឺ «ដងកើរ» គ្រាន់តែមានសូរសព្ទដូចពាក្យវៀតណាម ឬ តាមភាសាអ្នកស្រុកយើងនិយាយថា «កើល» មានន័យថា ធ្វើឱ្យទ័ល ធ្វើឱ្យខ្ពស់បំផុត «កើល ឬ ទើស» ដងកើរ គឺដងទង់ដែលផុតខ្ពស់មេឃ គឺកើលនឹងមេឃ ។

មជ្ឈដ្ឋានខ្លះនិយាយថា : ដងកើនេះឈ្មោះពិតប្រាកដដំបូងបំផុត គឺ ដងកល្ប គឺជាដងទង់ព្រះរាជសង្ហារ ជានិមិត្តរូបនៃការកំណត់រជ្ជកាលរបស់ព្រះមហាក្សត្រ ។ កល្ប ភាសាសំស្ក្រឹតក្លាយពីភាសាបាលីថា កប្ប ប្រែថា កាលដែលតាំងនៅយូរអង្វែង ។ ដោយសារនៅទីនេះមានកំពង់ផែដ៏ធំមួយ ជាទីប្រជុំចុះនៃមហាជនគ្រប់សាសន៍ខ្មែរ ចិន វៀតណាម ចាម ជ្វា ក្នុងអាជីវកម្មការឆ្លងទៅឆ្លងមករវាងភាសានៃជនជាតិមួយទៅជនជាតិមួយតែងតែមានចៀសមិនផុត ។ វៀតណាម អានពាក្យ កល្ប មិនច្បាស់ទៅជាអានថា កើ ស្របនឹងពាក្យវៀតណាម កើ ប្រែថា ទង់ បានជាបណ្ដើរៗបាត់ពាក្យដងកល្ប ក្លាយជាពាក្យដងកើរហូតដល់សព្វថ្ងៃ ។

ទោះបីជាមិនមានឯកសារណាមួយបញ្ជាក់ឱ្យបានច្បាស់លាស់ក៏ដោយ ក៏ទាំងនេះអាចជាមូលដ្ឋានពិចារណា សម្រាប់កូនចៅជំនាន់ក្រោយផងដែរ ។ ទាក់ទិននឹងបញ្ហានេះដែរ លោក អ៊ំ ហាក់ ស៊ុន អ្នកថែរក្សាប្រចាំនៅអាស្រមព្រះអង្គដងកើបានមានប្រសាសន៍ថា បារមីរបស់ព្រះអង្គបានដឹកនាំចិត្តប្រជាជនឱ្យនឹកឃើញចង់ធ្វើអ្វីដែលល្អ ដែលស្របទៅនឹងឃ្លារបស់ព្រះអង្គថា «ធ្វើល្អបានល្អ» យើងប្រព្រឹត្តអំពើអ្វី យើងនឹងទទួលផលនោះវិញ ។

លោកអ៊ំបានបញ្ជាក់ដែរថា ថ្ងៃសីលវិញមានប្រជាជនច្រើនណាស់រហូតដល់រាប់ពាន់នាក់ ពីព្រោះគេមានជំនឿលើស្នាដៃរបស់ព្រះអង្គដែលតែងតែជួយថែរក្សាកូនចៅរហូតមក ។ លោកអ៊ំមានប្រសាសន៍បន្តថា «ខ្ញុំជឿជាក់លើការបន់ស្រន់ប៉ុន្មានថ្ងៃមុនពីជំងឺរបស់អ្នកស្រីម្នាក់ក្រោយពីការបន់ស្រន់ប៉ុន្មានថ្ងៃ គាត់ក៏បានយករបស់របរដូចជា ជ្រូង ផ្កា មកថ្វាយ ហើយបានប្រាប់ថាកូនគាត់ជាសះស្បើយហើយ» ។

លោក ប្រាក់ និមល សន្តិសុខប្រចាំអាស្រមបានលើកឡើងថា «ខ្ញុំពិបាកណាស់រៀងរាល់ថ្ងៃសីល ពីព្រោះថ្ងៃសីលខ្លះមានភ្ញៀវទេសចរច្រើន អ្វីដែលគួរឱ្យបារម្ភគឺក្មេងសុំទានតែងបង្កភាពរញ៉េរញ៉ៃ» ។ លោកក៏បានបញ្ជាក់ផងដែរថា ទោះបីពេលខ្លះលោកពិបាកក្នុងការការពារសុវត្ថិភាពជូនប្រជាពលរដ្ឋក៏ដោយ ក៏លោកនៅតែមិនរអែអង់ក្នុងការការពារអាស្រមនេះដែរ ។

លោក ហេង សំអាត ជាអ្នកលក់ចាបបានមានប្រសាសន៍ថា ប្រជាជនទិញចាបលែង ព្រោះពួកគេយកនិមិត្តរូបដែលពួកលែងចាបពីទ្រុង គេសូមឱ្យទុក្ខលំបាកទាំងប៉ុន្មានរសាត់ចេញពីចិត្តរបស់គេ ដូចចាបបានហោះចេញពីទ្រុងអ៊ីចឹង ។ ខ្លះទៅក៏សូមឱ្យចាបនោះហោះទៅទាំងគូដោយមិនចែកផ្លូវគ្នាដែលពួកគេតំណាងថា គូជីវិតរបស់ពួកគេមានវាសនាល្អដូចគ្នាដែរ ។

អ្នកស្រី ទី ពៅបុនឡាង មិនថាអ្នកស្រីមានទុក្ខកង្វល់អ្វីនោះទេ អ្នកស្រីតែងតែមកធ្វើការបន់ស្រន់សូមឱ្យព្រះអង្គជួយ ។ អ្នកស្រីបានលើកឡើងថា «ប៉ុន្មានថ្ងៃមុនមាន់ឈឺស្លាប់ច្រើនពេក ខ្ញុំបានមកធ្វើការបន់ស្រន់ស្រាប់តែស្អែកចំនួននៃមាន់មានការថយចុះ នេះពិតជាធ្វើឱ្យខ្ញុំជឿយ៉ាងស៊ប់ មួន» ៕

រស់ សុធា